# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ:……… ស.ខ.ក.ក.

## សេចក្ដីអំពាវនាវ

ថ្ងៃទី០១ខែកញ្ញាឆ្នាំ២០១៤ ជាថ្ងៃផុតកំណត់នៃការផ្អាក់ធ្វើបាតុកម្មបណ្ដោះអាសន្ន របស់សហគមន៍ខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ ដើម្បីទុកពេលជូនក្រសួងការបរទេសខ្មែរ ធ្វើការជាមួយរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម។ តែរហូតមកដល់ពេលនេះ យើងខ្ញុំពុំបានទទួលចម្លើយអ្វីទាំងអស់។

យោងស្មារតីអង្គប្រជុំរបស់អង្គការ-សមាគមខ្មែរកម្ពុជាក្រោមថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ និងស្មារតីអង្គប្រជុំរបស់សម្ព័ន្ធយុវជនខ្មែរដើម្បីប្រជាធិបតេយ្យ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៤ បានសំរេចកំណត់យកថ្ងៃទី០១-០២-០៣-០៤និងទី០៥ ខែតុលា ឆ្នាំ២០១៤ ជាថ្ងៃធ្វើមហាបាតុកម្មជាបន្តទៀត។ ពីព្រោះនៅខែកញ្ញានេះប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស នឹងប្រារព្ធពិធីបុណ្យប្រពៃណីជាតិមួយដ៏សំខាន់គឺ បុណ្យកាន់បិណ្ឌ និងបុណ្យភ្ជុំបិណ្ឌ។

មុននិងចូលរួមប្រារព្ធពិធីបុណ្យប្រពៃណីជាតិដ៏សំខាន់នេះ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ បានសំរេចរៀបចំវេទិកាសាធារណៈមួយនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៤ នា ទីលានប្រជាធិបតេយ្យក្បែរវត្តភ្នំ ចាប់ពីម៉ោង០៨ព្រឹករហូតម៉ោង៥ល្ងាច ដើម្បីផ្ដល់ឱកាសប្រគេនព្រះករុណាគ្រប់ព្រះអង្គនិងជូនបងប្អូនរួមជាតិបញ្ចេញមតិលើប្រធានបទ ប្រវត្តិទឹកដីកម្ពុជាក្រោមនិងការអនុវត្តន៍ច្បាប់អន្តោប្រវេសន៍នៅព្រះរាជាណាចក្រកម្ពុជា។

ដើម្បីសំរេចការងារដ៏សំខាន់ ដូចបានប្រគេន និងជំរាបជូនខាងលើ អាស្រ័យទៅលើស្មារតីនិមន្ត និងអញ្ជើញចូលរួម ព្រមទាំងវិភាគទាន របស់ព្រះករុណាគ្រប់ព្រះអង្គ និងបងប្អូនរួមជាតិទាំងស្រុង។

អាស្រ័យហេតុនេះ ខ្ញុំព្រះករុណាខ្ញុំ សូមលំឱនកាយក្រាបថ្វាយបង្គំអារាធនានិមន្តព្រះករុណាគ្រប់ព្រះអង្គ បងប្អូនរួមជាតិទាំងអស់ ព្រះមេត្តា និងមេត្តានិមន្ត និងអញ្ជើញចូលរួមឲ្យបានច្រើនកុះករ និងជួយចូលរួមវិភាគទានតាមសទ្ធាជ្រះថ្លា ជាសម្ភារៈ ជាចង្ហាន់ព្រះសង្ឃ ជាបាយកញ្ចប់ ជាទឹកបរិសុទ្ធ ជាថវិការដើម្បីផ្ដល់លទ្ធភាពដល់យើងខ្ញុំ ក្នុងការរៀបចំវេទិកានេះ បានជោគជ័យតាមការគួរ។

សូមព្រះករុណាគ្រប់ព្រះអង្គ និង បងប្អូនរួមជាតិទាំងអស់ព្រះមេត្តានិងមេត្តាទទួលនូវការគោរពនិងស្រឡាញ់ដ៏ជ្រាលជ្រៅអំពីយើងខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤

តំណាងគណៈកម្មការរៀបចំវេទិកាសាធារណៈ

**ថាច់ សេដ្ឋា**

ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម

អតីតសមាជិកព្រឹទ្ធសភា

ទីស្នាក់ការផ្ទះលេខ៖ ៧២ ផ្លូវលេខ ៤២៦A, ភូមិគោគឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ០១២ ៩០៨ ៨៨២ /៩៣ ៤៧ ៤៧ ០៦
E-mail: thachsetha13@gmail.com Website: www.khmerkromngo.org

# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ៦៥/១៤ ស.ខ.ក.ក.

## គោរពជូន

**ឯកឧត្តមប៉ា សុជាតិវង្ស**
**អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ**

**កម្មវត្ថុ:** ជូនដំណឹងស្តីអំពីការធ្វើវេទិកាសាធារណៈ នៅទីលានប្រជាធិបតេយ្យ

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា សហគមន៍ខ្មែរកម្ពុជាក្រោមនិងសម្ព័ន្ធយុវជនខ្មែរដើម្បីប្រជាធិបតេយ្យនឹងរៀបចំធ្វើវេទិកាសាធារណៈនៅទីលានប្រជាធិបតេយ្យ ចាប់ពីម៉ោង៨:០០នាទីព្រឹករហូតដល់ម៉ោង៥:០០ល្ងាច ថ្ងៃទី០៦ ខែកញ្ញាឆ្នាំ២០១៤។ មនុស្សចូលរួម២០០នាក់ដោយមានដាក់កៅអីអង្គុយ និងសង់រោង។

ប្រធានបទ ទឹកដីកម្ពុជាក្រោម និង ការអនុវត្តច្បាប់អន្តោប្រវេសន៍ នៅព្រះរាជាណាចក្រកម្ពុជា។

វាគ្មិន ការអនុវត្តន៍ច្បាប់អន្តោប្រវេសន៍ មកពីក្រសួងមហាផ្ទៃ (មិនទាន់មានការឆ្លើយតប)

លោក សុខ សំអឿន អ្នកច្បាប់

លោក ថាច់ សេដ្ឋា ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម អតីតសមាជិកព្រឹទ្ធសភា

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាជ្រាប និងជួយចាត់វិធានការ ការពារសន្តិសុខសណ្តាប់ធ្នាប់ដល់វេទិកាសាធារណៈរបស់យើងខ្ញុំដោយអនុគ្រោះ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃច័ន្ទទី០១ ខែកញ្ញា ឆ្នាំ២០១៤

នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

**ថាច់ សេដ្ឋា**

អតីតសមាជិកព្រឹទ្ធសភា


ទីស្នាក់ការផ្ទះលេខ៖ ៧២ ផ្លូវលេខ ៤២៦A, ភូមិគោគឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ០១២ ៩០៤ ៨៨២ /៩៣ ៨៧ ៨៧ ០៦
E-mail: thachsetha13@gmail.com Website: www.khmerkromngo.org

# សហគមន៍ខ្មែរកម្ពុជាក្រោម

THE KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTÉ DU KHMER KAMPUCHEA KROM

លេខ០៦៤/១៤ ស.ខ.ក.ក.

## គោរពជូន
## ឯកឧត្តម ស ខេង
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**កម្មវត្ថុ:** សំណើសុំអញ្ជើញតំណាងក្រសួងមហាផ្ទៃ១រូប ធ្វើជាវាគ្មិន លើប្រធានបទ ការអនុវត្តន៍ច្បាប់អន្តោប្រវេសន៍ នៅព្រះរាជាណាចក្រកម្ពុជា

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថាដើម្បីចូលរួមចំណែកនិងស្វែងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ នៅព្រះរាជាណាក្រកម្ពុជា សហគមន៍ខ្មែរកម្ពុជាក្រោមបានរៀបចំវេទិកាសាធារណៈមួយ ក្រោមប្រធានបទ ប្រវត្តិទឹកដីកម្ពុជាក្រោម នឹង ការអនុវត្តច្បាប់អន្តោប្រវេសន៍នៅព្រះរាជាណាចក្រកម្ពុជា។ វេទិកានេះ និងរៀបចំនៅ ទីលានប្រជាធិបតេយ្យ ចាប់ពីម៉ោង៨ព្រឹករហូតម៉ោង២រសៀល ថ្ងៃទី០៦ខែកញ្ញាឆ្នាំ២០១៤។

អាស្រ័យហេតុនេះ សហគមន៍ខ្មែរកម្ពុជាក្រោម សូមអនុញ្ញាតគោរពអញ្ជើញតំណាងក្រសួងមហាផ្ទៃ១រូប ធ្វើជាវាគ្មិន លើប្រធានបទ ការអនុវត្តច្បាប់អន្តោប្រវេសន៍ នៅព្រះរាជាណាចក្រកម្ពុជា។

សេចក្តីដូចបានជំរាបជូនខាងលើ សូមឯកឧត្តមមេត្តាចាត់តំណាងក្រសួងមហាផ្ទៃ១រូប មកចូលរួមធ្វើជាវាគ្មិនក្នុងវេទិកាសាធារណៈរបស់យើងខ្ញុំដោយអនុគ្រោះ។

យើងខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តមពិតជាផ្តល់កិត្តិយសដល់ សហគមន៍ខ្មែរកម្ពុជាក្រោម ដោយចាត់តំណាងមកចូលរួមធ្វើជាវាគ្មិនក្នុងកម្មវិធីរបស់យើងខ្ញុំជាក់ជាមិនខាន។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញថ្ងៃទី០២ខែកញ្ញាឆ្នាំ២០១៤
ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម

**ថាច់ សេដ្ឋា**
អតីតសមាជិកព្រឹទ្ធសភា


ទីស្នាក់ការផ្ទះលេខ៖ ៧២ ផ្លូវលេខ ៤២៦A, ភូមិគោកឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ០១២ ៩០៨ ៨៨២ /៩៣ ៤៧ ៤៧ ០៦
E-mail: thachsetha13@gmail.com Website: www.khmerkromngo.org